# អត្ថបទស្រាវជ្រាវ និង វិភាគ

អត្ថបទដកស្រង់ចេញពីព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌ លេខ ២
បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌




# សារការីនៅក្នុងនីតិកម្ពុជា

រៀបចំដោយៈ

-លោកស្រី **នៅ សុជាតា** សារការី និងជានាយករងសាលាភូមិន្ទសារការី

សញ្ញាណសារការី និង លិខិតយថាភូតដែលធ្វើឡើងដោយសារការី បានចាប់កំណើតដំបូងឡើយនៅក្នុងនីតិកម្ពុជា តាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ ដោយសារការតាក់តែងច្បាប់រដ្ឋប្បវេណីខ្មែរនាសម័យនោះ ត្រូវបានជួយជ្រោមជ្រែងដោយអាជ្ញាធរបារាំង ទើបធ្វើឱ្យច្បាប់ខ្មែរប្រកាន់យកប្រព័ន្ធច្បាប់រ៉ូម៉ាំង[1]។ ហេតុនេះ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ទទួលឥទ្ធិពលស្ទើរទាំងស្រុងពីក្រមរដ្ឋប្បវេណីបារាំងឆ្នាំ ១៨០៤។ សញ្ញាណនៃសារការីនៅកម្ពុជានាពេលនោះក៏បានយកលំនាំតាមប្រព័ន្ធសារការីរបស់បារាំងផងដែរ។ ផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ១៩២០, សារការី គឺជាមន្ត្រីសាធារណៈដែលរាជការបារាំងបានតែងតាំងឱ្យធ្វើជាសារការីផង ឬដែលរាជការបារាំងបានអនុញ្ញាតឱ្យធ្វើជាបណ្តោះអាសន្នផង ក្រោយពីការផ្ទេរសមត្ថកិច្ចមកជូនរដ្ឋាភិបាលខ្មែរពេញផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាទំរាំមានសេចក្តីសម្រេចអំពីរឿងនេះជាថ្មីទៀត[2]។ សារការីមានសមត្ថកិច្ចធ្វើលិខិតបញ្ជាក់តាមរូបមន្តយថាភូត។ លិខិតតាមរូបមន្តយថាភូត គឺជាលិខិត **“មានបញ្ជាក់ ឬធ្វើនៅសារការី**[3]”។ ហេតុដូចនេះ លិខិតយថាភូត សំដៅដល់ទាំងលិខិតបញ្ជាក់ដែលធ្វើឡើងដោយមេឃុំ ឬចៅហ្វាយស្រុក និងលិខិតយថាភូតដែលធ្វើនៅសារការី។ ច្បាប់នាសម័យនោះ តម្រូវឱ្យមានការតាក់តែងជាទម្រង់លិខិតយថាភូតដែលធ្វើនៅសារការីសម្រាប់ប្រតិបត្តិការមួយចំនួន ជាអាទិ៍ កិច្ចសន្យាផលុបភោគ[4], កិច្ចសន្យាលក់[5] ឬផ្ទេរនូវកម្មសិទ្ធិលើ

---

1. BALIVET Béatrice, « Le droit Cambodgien et les grandes familles du droit », Introduction au droit cambodgien, Phnom Penh, éd. Funan, ២០០៥, ទំព័រ ២២។

2. កថាខណ្ឌទី២ នៃមាត្រា៩៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ចែងថា “*លិខិតទាំងពួងដែលមន្ត្រីសាធារណៈបានធ្វើតាមរូបមន្តយថាភូត។ មន្ត្រីសាធារណៈនោះគឺ សារការី ក្រឡាបញ្ជី ដែលរាជការបារាំងបានតែងតាំងឲ្យធ្វើជាសារការីផង ឬដែលរាជការបារាំងបានអនុញ្ញាតឱ្យធ្វើជាបណ្តោះអាសន្នក្រោយពីការផ្ទេរសមត្ថកិច្ចមកជូនរដ្ឋាភិបាលខ្មែរពេញផ្ទៃនៃព្រះរាជាណាចក្រ ទំរាំមានសេចក្តីសម្រេចអំពីរឿងនេះជាថ្មីម្តងទៀត*”។ សូមមើលក្នុងសៀវភៅៈ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

3. ជាអាទិ៍ មាត្រា៧២៨, មាត្រា៨៣៧, មាត្រា១០២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ សូមមើលក្នុងសៀវភៅៈ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

4. កថាខណ្ឌទី២ នៃមាត្រា ៧២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ “*កិច្ចសន្យាអំពីផលុបភោគ នឹងយកជាទីអាងបាន, សូម្បីតែរវាងភាគីផងគ្នាក៏ដោយ, ក៏ត្រូវធ្វើជាលិខិតតាមរូបមន្តយថាភូតដែរ (គឺមានបញ្ជាក់ ឬធ្វើនៅសារការី) លិខិតនេះនឹងយកជាទីអាងចំពោះតតីយជនបានតែនៅពេលដែលិខិតនេះចុះក្នុងបញ្ជីការអ៊ីម្មាទ្រីគុឡាស្យុងរួចហើយ។ នេះចំពោះតែកិច្ចសន្យាដែលទាក់ទងនឹងអចលនវត្ថុជាកម្មសិទ្ធិ*”។ សូមមើលក្នុងសៀវភៅៈ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

5. កថាខណ្ឌទី២ នៃមាត្រា ១០២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ “*ក៏ប៉ុន្តែការលក់នូវសិទ្ធិប្រត្យ័ក្ស អចលនវត្ថុនឹងត្រូវចាត់ទុកថាជាមានបន្ទាល់ រវាងភាគីផងគ្នា ឬរវាងតតិយជនបាន ក៏លុះណាតែការលក់នោះបានធ្វើជាលាយល័ក្សអក្សរតាមរូបមន្តយថាភូត គឺមានបញ្ជាក់*

អចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុ[6], កិច្ចសន្យាហ៊ីប៉ូតែក[7]។ សារការីមានសមត្ថកិច្ចធ្វើលិខិតបញ្ជាក់ចំពោះលិខិតទាំងឡាយណាដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០ ០០០ រៀលឡើងទៅ[8] ព្រោះជាប្រភេទប្រតិបត្តិការដែលមានតម្លៃខ្ពស់ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ខ្លាំងក្នុងការទាមទារឱ្យមានការបញ្ជាក់ផ្ទៀងផ្ទាត់ដោយល្អិតល្អន់ពីអ្នកជំនាញច្បាប់ក្នុងគោលបំណងការពារផលប្រយោជន៍ដល់គូភាគី។ លិខិតដែលមានតម្លៃចន្លោះពី ៥០ ០០០រៀលដល់ ២០០ ០០០រៀល គឺចៅហ្វាយស្រុកជាអ្នកបញ្ជាក់។ លិខិតដែលមានតម្លៃក្រោមពី ៥០ ០០០រៀលចុះមក ភាគីចង់យកទៅឱ្យមេឃុំ ឬចៅហ្វាយស្រុកបញ្ជាក់ក៏បាន ឬឱ្យសារការីបញ្ជាក់ក៏បាន[9]។

ទោះបីសារការីត្រូវបានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ក៏ដោយ ប៉ុន្តែ យើងត្រូវរង់ចាំរហូតដល់ឆ្នាំ ១៩៥៤ ទើបច្បាប់ស្តីពីវិជ្ជាជីវៈសារការី នៅកម្ពុជា ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។ ផ្អែកតាមមាត្រា៦ នៃព្រះរាជក្រមនេះ, មន្ទីរសារការីមួយត្រូវបង្កើតឡើងនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចធ្វើលិខិតតុបករណ៍នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ប៉ុន្តែ ផ្អែកតាមតម្រូវការចាំបាច់, គណៈរដ្ឋមន្ត្រីអាចបង្កើនចំនួនមន្ទីរសារការីរហូតដល់ ៥ កន្លែងនៅទូទាំងប្រទេស ដោយព្រះរាជក្រឹត្យ តាមសំណើរបស់

---

*ឬធ្វើនៅសារការី*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

6. មាត្រា៨៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ការដែលផ្ទេរនូវកម្មសិទ្ធិអចលនវត្ថុ និងសិទ្ធិប្រត្យក្សអចលនវត្ថុនោះ នឹងទុកជាភស្តុតាងរវាងភាគីបានលុះត្រាតែការនោះបានធ្វើជាសំបុត្រយថាភូតគឺចុះសេចក្តីបញ្ជាក់ ឬធ្វើនៅសារការី។ បើផ្ទេរអចលនវត្ថុអ៊ីម៉ាទ្រីគុឡាស្យុងផង សំបុត្រយថាភូតនេះត្រូវចុះក្នុងបញ្ជីការអ៊ីម៉ាទ្រីគុឡាស្យុងទៀត ទើបតតិយជនមិនអាចតវ៉ាបាន*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

7. មាត្រា ១៣៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ហ៊ីប៉ូតែកជាកិច្ចសន្យាដែលត្រូវប្រតិបត្តិតាមល័ក្ខខណ្ឌនៃច្បាប់បារាំង ដែលស្តីពីធ្វើបែបណាដែលទុកថាត្រឹមត្រូវគឺថាត្រូវធ្វើនៅសារការីបើមិនដូច្នោះទេត្រូវទុកជាមោឃៈជាដាច់ខាត*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

8. កថាខណ្ឌ៣ នៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ក៏ប៉ុន្តែលិខិតទាំងឡាយគ្រប់ប្រភេទ ដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០ ០០០ រៀល ឡើងទៅត្រូវតែឲ្យសារការីបញ្ជាក់តាមទម្រង់នៃអាជីវកម្មរបស់គេ*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

9. កថាខណ្ឌ៥ នៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ក្រោមពី ៥០ ០០០រៀលចុះមក ភាគីចង់យកទៅឲ្យមេឃុំ ឬ ចៅហ្វាយស្រុកបញ្ជាក់ក៏បាន ឬ ឲ្យសារការីបញ្ជាក់ក៏បានតាមចិត្ត*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។ និង មាត្រា ៣ នៃព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ លើមូលដ្ឋាននេះ, ព្រះរាជក្រឹត្យលេខ ១២៩ ប.វ. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៨ បានកំណត់ឱ្យមានមន្ទីរសារការីសរុបចំនួន ៥ ដោយក្នុងនោះមន្ទីរសារការីចំនួន ២ ត្រូវមានទីស្នាក់ការនៅក្រុងភ្នំពេញ និងមន្ទីរសារការី ៣ ទៀត បង្កើតនៅខេត្តបាត់ដំបង, ខេត្តកំពត និង ខេត្តកំពង់ចាម។ ព្រះរាជក្រមឆ្នាំ១៩៥៤ បានអនុម័តយកប្រព័ន្ធសារការីតាមប្រព័ន្ធរ៉ូម៉ាំង[10] ឬប្រព័ន្ធច្បាប់ Civil Law ដោយបានបញ្ញត្តិក្នុងមាត្រា១ ថា សារការី គឺជា "មន្ត្រីសាធារណៈដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យរបស់រាជរដ្ឋាភិបាល និងបង្កើតឡើងក្នុងគោលបំណងចំនួន ២ គឺ (១)-ដើម្បីទទួល និងក្នុងករណីចាំបាច់ តាក់តែងលិខិត ឬកិច្ចសន្យានានាដែលគូភាគីត្រូវតែ ឬចង់ឱ្យមានការផ្តល់ចរិតយថាភាពដែលនៅជាប់ជាមួយនឹងលិខិតរបស់អាជ្ញាធរសាធារណៈ និង (២)-ដើម្បីបញ្ជាក់នូវកាលបរិច្ឆេទនៃលិខិត, រក្សាទុកលិខិតជាបញ្ញើ, ប្រគល់ឱ្យនូវសេចក្តីចម្លង និងការចម្លងបញ្ជាក់នៃលិខិតទាំងនោះ។ សារការីត្រូវបំភ្លឺ, ជូនដំណឹង និងផ្តល់ប្រឹក្សាយោបល់ដល់គូភាគីទាក់ទងនឹងលិខិតដែលពួកគាត់បានធ្វើ ឬដែលពួកគាត់មានបំណងធ្វើ ហើយក្នុងនាមជាមន្ត្រីសាធារណៈ សារការីត្រូវធានាអះអាងថា និទ្ទេសនៃលិខិតទាំងនោះស្របគ្នាយ៉ាងពិតប្រាកដទៅនឹងតថភាព"។ មាត្រា៣ នៃព្រះរាជក្រមនេះ បានបញ្ជាក់ឡើងវិញអំពីសមត្ថកិច្ចផ្តាច់មុខរបស់សារការីដែលអាចធ្វើការបញ្ជាក់តាមទម្រង់នៃវិជ្ជាជីវៈរបស់ខ្លួនចំពោះលិខិតទាំងឡាយណាដែលមានតម្លៃស្មើ ឬចាប់ពី ២០០ ០០០ រៀល[11]។

---

10. នៅសតវត្សទី ៣ នៅក្នុងចក្រភពរ៉ូម៉ាំង មានមុខងារមន្ត្រីរាជការបំពេញការងារទទួលបញ្ជាក់លើកិច្ចសន្យាក្នុងនាមរដ្ឋ និងមានប្រព័ន្ធរក្សាទុកលិខិតដែលខ្លួនធ្វើនោះ ស្រដៀងមុខងារសារការីបច្ចុប្បន្ន។ ការដាក់អាណានិគមនិយមរបស់រ៉ូម៉ាំង ផ្តល់នាទីសំខាន់ដល់ "មន្ត្រីរាជការបែបសារការី" នេះ ក្នុងការចុះបញ្ជីដីធ្លី និងកំណត់មូលដ្ឋានទារពន្ធ។ នៅស្រុកបារាំង សារការីដើរតួនាទីសំខាន់ខ្លាំងដែលរដ្ឋផ្តល់ឱ្យតាំងពីឆ្នាំ១២៧០ (Saint Louis) និង ១៣០២ (Philippe le Bel)៖ តែងតាំង និងពង្រាយទូទាំងប្រទេស។ ក្រោយបដិវត្តន៍បារាំង សារការីកាន់តែមានសារៈសំខាន់និងទទួលបានជំនឿទុកចិត្តកាន់តែច្រើនពីសង្គមបារាំងដែលគ្មានស្តេច។ ស្តេចណាប៉ូឡេអុងផ្តល់ដល់សារការីបារាំងនូវលក្ខន្តិកៈដែលប្រើរហូតមកដល់បច្ចុប្បន្ន (loi du 25 ventôse an XI)។ អាណានិគមបារាំង និងនៃប្រទេសអឺរ៉ុបផ្សេងទៀតបាននាំប្រព័ន្ធសារការីដល់អាម៉េរិក, អាហ្វ្រិច និងអាស៊ី។

11. កថាខណ្ឌទី៣ នៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ចែងថា "*ក៏ប៉ុន្តែលិខិតទាំងឡាយគ្រប់ប្រភេទ ដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០ ០០០រៀលឡើងទៅត្រូវតែឱ្យសារការីបញ្ជាក់តាមទម្រង់នៃអាជីវកម្មរបស់គេ*"។ សូមមើលក្នុងសៀវភៅ៖ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។ មាត្រា ៣ នៃព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។

វិជ្ជាជីវៈសារការីនៅកម្ពុជា ត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វិជ្ជាជីវៈសារការីនេះ ទើបត្រូវបានបង្កើតឱ្យមានឡើងវិញតាមរយៈអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា២ នៃអនុក្រឹត្យនេះ បានកំណត់ថា *"មេធាវីសារការី ជាមន្ត្រីសាធារណៈទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ"*។ ការតែងតាំងឱ្យមានជាមេធាវីសារការីនេះ មានលក្ខណៈប្រហាក់ប្រហែលនឹងមុខងាររបស់ "Solicitor" នៅក្នុងប្រព័ន្ធច្បាប់ Common Law ដែលស្មាក្តី "Solicitor" គឺជាអ្នកផ្តល់យោបល់ផ្នែកច្បាប់ ទោះជាមាន ឬគ្មានវិវាទ ទាំងច្បាប់សាធារណៈ និងច្បាប់ឯកជន[12]។ ផ្អែកតាមមាត្រា ៣ នៃអនុក្រឹត្យនេះ មេធាវីសារការីមានសមត្ថកិច្ចទូទៅក្នុងវិស័យផ្នែកគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ ហើយធ្វើនូវកិច្ចការជាអាទិ៍៖ (ក)-ទទួល និងធ្វើ ឬចារិកបញ្ជាក់ និងប្រថាប់ត្រានូវលិខិតស្នាមគតិយុត្ត ឬកិច្ចសន្យាទាំងឡាយ ដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ និង (ខ)-ធ្វើការបញ្ជាក់លើកាលបរិច្ឆេទ, ទទួលតម្កល់ឯកសារ និងចេញឱ្យនូវសេចក្តីដើម ឬសេចក្តីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ។

ក្រោយពេលដែលក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវបានអនុម័ត និងចូលជាធរមាន, សារការីកាន់តែមានតួនាទីសំខាន់ៗឡើងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដោយច្បាប់បានកំណត់ឱ្យប្រតិបត្តិការគតិយុត្តមួយចំនួនត្រូវតែធ្វើឡើងតាមទម្រង់លិខិតយថាភូតដែលធ្វើឡើងដោយសារការី។ ទន្ទឹមនឹងនេះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៦ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានផ្តល់តម្លៃគតិយុត្តជាបន្ទាល់ និងផ្តល់នូវអានុភាពជាលិខិតអនុវត្តចំពោះលិខិតគតិយុត្តមួយចំនួនដែលតាក់តែងឡើងដោយសារការី ហើយដែលមានតម្លៃដូចជាសាលក្រមស្ថាពររបស់តុលាការផងដែរ។ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បានកំណត់អំពីអត្ថន័យនៃលិខិតយថាភូត[13] និងភារកិច្ចបណ្តោះអាសន្នតាមតម្រូវការចាំបាច់ ព្រមទាំង

---

[12]. BALIVET Béatrice, *« Le droit Cambodgien et les grandes familles du droit », Introduction au droit cambodgien*, Phnom Penh, éd. Funan, ២០០៥, ទំព័រ ២២។

[13]. មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានកំណត់អំពីអត្ថន័យនៃលិខិតយថាភូត។

សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី[14]។ បន្ទាប់ពីមានក្រមទាំង ២ នេះ, មន្ទីរសារការីមួយចំនួនធំទៀត[15] ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ដោយអនុក្រឹត្យ ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់ក្នុងការអនុវត្តក្រមទាំង២ នេះ និងច្បាប់ជាធរមានផ្សេងទៀត។ បច្ចុប្បន្ន វិជ្ជាជីវៈសារការីបានក្លាយជាវិជ្ជាជីវៈច្បាប់មួយដែលត្រូវបានទទួលស្គាល់ និងបានចាប់ផ្តើមចាក់ឫសជាថ្មីឡើងវិញជាបណ្តើរៗនៅក្នុងសង្គមកម្ពុជា។ ផ្អែកតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន តើសារការីមានមុខងារ និងសមត្ថកិច្ចអ្វីខ្លះ **(១)**? និង តើប្រតិបត្តិការគតិយុត្តក្នុងវិស័យណាខ្លះដែលច្បាប់តម្រូវឱ្យធ្វើឡើងដោយសារការី **(២)**?

## ១- អំពីមុខងាររបស់សារការី

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ច្បាប់ក្នុងវិស័យយុត្តិធម៌, ក្រសួងយុត្តិធម៌បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ដែលនឹងកំណត់ឱ្យបានច្បាស់លាស់អំពីលក្ខន្តិកៈសារការី និងវិជ្ជាជីវៈសារការី។ ដោយសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការីមិនទាន់ត្រូវបានរៀបចំរួចរាល់នៅឡើយ, សារការីនៅមិនទាន់មានក្របខ័ណ្ឌគតិយុត្តរួមមួយជាក់លាក់នៅឡើយទេ។ បច្ចុប្បន្ន សារការីស្ថិតក្រោមវិធានដែលត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងៗទៀត។ ផ្អែកតាមលិខិតបទដ្ឋានទាំងនេះ សារការីគឺជាមន្ត្រីសាធារណៈផង **(ក)** និងជាអ្នកប្រកបវិជ្ជាជីវៈសេរីផង **(ខ)** ។

### ក- សារការីគឺជាមន្ត្រីសាធារណៈ

មាត្រា២ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ បានកំណត់ថា “**មេធាវីសារការី ជាមន្ត្រីសាធារណៈទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ**”។ មេធាវីសារការី គឺជាមន្ត្រីសាធារណៈដែលទទួលបាននូវប្រតិភូកម្ម

[14]. មាត្រា ១០ និងមាត្រា ១១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ បច្ចុប្បន្ន មន្ត្រីទទួលបន្ទុកកិច្ចការសារការី មានចំនួន ៤១ រូប (ប្រកាសលេខ៧២.កយ.ប្រក/១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ស្តីពីការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី)។

[15]. បច្ចុប្បន្ន មានមន្ទីរសារការីសរុបចំនួន ២ និងមានសារការីចំនួន ៦៩ រូប ដែលក្នុងនោះមាន ៦៨ រូប កំពុងប្រកបវិជ្ជាជីវៈសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អំណាចពីរដ្ឋ ដើម្បីធ្វើ ឬបញ្ជាក់នូវលិខិតគតិយុត្ត ឬកិច្ចសន្យាទាំងឡាយដែលមានតម្លៃជាបន្ទាល់ពេញលក្ខណៈតាមច្បាប់ដូចលិខិតរបស់រាជការសាធារណៈផងដែរ[16]។ ដោយឡែក អនុក្រឹត្យដែលបង្កើតមន្ទីរសារការីផ្សេងៗទៀត មិនបានកំណត់អំពីមុខងាររបស់សារការីនោះទេ ដោយគ្រាន់តែកំណត់អំពីតួនាទី និងភារកិច្ចរបស់មន្ទីរសារការីតែប៉ុណ្ណោះ។ តើសារការីដែលមិនមែនជាមេធាវី នៅតែត្រូវបានចាត់ទុកថាជាមន្ត្រីសាធារណៈតាមស្មារតីនៃអនុក្រឹត្យលេខ ៥០៥ ទៀតដែរឬទេ?

យោងតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ “**សារការី គឺជាមន្ត្រីសាធារណៈដែលមានមុខងារធ្វើលិខិតយថាភូត បញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឱ្យមានការបញ្ជាក់**”។ ផ្អែកតាមនិយមន័យនេះ សារការី គឺជាមន្ត្រីសាធារណៈ ត្រូវបានតែងតាំងដោយរដ្ឋ និងទទួលនូវប្រតិភូកម្មអំណាចពីរដ្ឋ ក្នុងការបំពេញមុខងារសំខាន់ៗចំនួន ៤ រួមមានៈ (ទី១)-ធ្វើលិខិតយថាភូត, (ទី២)-ធ្វើលិខិតបញ្ជាក់ពីលក្ខណៈពិតប្រាកដត្រឹមត្រូវ និងធានារ៉ាប់រងអំពីកាលបរិច្ឆេទ, (ទី៣)-តម្កល់ និងរក្សាទុកនូវលិខិតទាំងឡាយដែលបានធ្វើ ឬបានបញ្ជាក់ និង (ទី៤)-ចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងនោះ។ ក្រមរដ្ឋប្បវេណីនេះ បានបន្តកំណត់យកប្រព័ន្ធសារការីកម្ពុជា តាមប្រព័ន្ធសារការីនៃប្រព័ន្ធ Civil Law។ នៅក្នុងប្រព័ន្ធ Civil Law, សារការីគឺជាអ្នកជំនាញផ្នែកច្បាប់ និងជាមន្ត្រីសាធារណៈ ដែលទទួលបានការតែងតែងពីរដ្ឋដើម្បីផ្តល់យថាភូតភាពដល់កិច្ចសន្យារបស់គូភាគី និងផ្តល់នូវការប្រឹក្សាយោបល់ដោយមិនលម្អៀងដល់គូភាគីទាំងសងខាង។ សារការីតាក់តែងកិច្ចសន្យាដោយយោងទៅលើបទដ្ឋានគតិយុត្តជាធរមាន។ រដ្ឋបានធ្វើប្រតិភូកម្មដល់សារការីដែលត្រូវជាបុគ្គលមានគុណវុឌ្ឍិ គ្រប់គ្រាន់ដើម្បីអនុវត្តនូវបេសកម្មក្នុងការធានានូវសុវត្ថិភាពនៅក្នុងកិច្ចសន្យាតាមរយៈការផ្តល់នូវយថាភូតភាពដល់រាល់

16. ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បានរៀបរាប់លម្អិតអំពីមន្ត្រីរាជការសាធារណៈ អំពីតួនាទីនៃមន្ត្រីរាជការសាធារណៈ គឺបុគ្គលដែលទទួលបាននូវប្រតិភូកម្មអំណាចសាធារណៈពីរដ្ឋ ក្នុងការបញ្ជាក់នូវលិខិតទាំងឡាយដែលមានកំណត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ (មាត្រា ៩៤៤ ដល់មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០)។ មន្ត្រីរាជការសារធារណៈ គឺជាបុគ្គលដែលមានសមត្ថភាពដើម្បីបញ្ជាក់នូវលិខិតទាំងឡាយក្នុងឃុំនីមួយៗនោះ គឺមេឃុំ បើមេឃុំមិននៅ ឬមានធុរៈ ត្រូវជំទប់ណាមួយក្នុងឃុំជំនួស កុំឱ្យតែការនេះប៉ះពាល់សិទ្ធិនិងដល់សិទ្ធិផ្តាច់មុខដែលបានសំដែងហើយក្នុងមាត្រានេះដើម្បីជាផលប្រយោជន៍ដល់មន្ត្រីរាជការសាធារណៈដទៃទៀត។ សូមមើលក្នុងសៀវភៅៈ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

លិខិតដែលខ្លួនបានតាក់តែង។ ទម្រង់យថាភូត គឺជាយន្តការសម្រាប់ការពារនូវឆន្ទៈរបស់បុគ្គលម្នាក់ៗដើម្បីធានាថាឆន្ទៈរបស់គូភាគីត្រូវបានបង្ហាញឡើងដោយសេរី មិនស្ថិតក្រោមការបង្ខិតបង្ខំ និងមិនមានការភ័ន្តច្រលំ។ លិខិតធ្វើដោយសារការី ត្រូវបានកំណត់ថាជាលិខិតសារការី ដែលរួមមាន *“លិខិតយថាភូត”* និង *“លិខិតបញ្ជាក់”*។

- **លិខិតបញ្ជាក់៖** យោងមាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណី ដែលហៅថា លិខិតបញ្ជាក់នោះ គឺសំបុត្រដែលគូភាគីបានចុះហត្ថលេខាក្រោយដែលគេបានអានសេចក្ដីសំបុត្រទាំងអស់យ៉ាងខ្លាំងៗដោយក្បោះក្បាយឱ្យគូភាគីស្ដាប់ចំពោះមុខមន្ត្រីរាជការសាធារណៈនេះ ក្រោយដែលបានពិនិត្យអំពីអត្តសញ្ញាណនៃគូភាគី អំពីការចូលខ្លួននៃគូភាគី អំពីការអានលិខិតឲ្យគូភាគីស្ដាប់ អំពីហត្ថលេខា ដែលភាគីបានចុះនោះឃើញថាត្រឹមត្រូវហើយ ទើបចុះហត្ថលេខាខ្លួនឯងក្បែរហត្ថលេខានៃគូភាគីព្រមទាំងបោះត្រាផង។

- **លិខិតយថាភូត៖** សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានឱ្យនិយមន័យនៃ *“លិខិតយថាភូត គឺជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី”* ផ្ទុយពីលិខិតឯកជនដែលជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជនដោយមានចុះហត្ថលេខា ឬស្នាមមេដៃ។ យោងតាមមាត្រា ៩ ចំណុច ក វាក្យខណ្ឌទី១ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បានចែងថា *“ លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦, មាត្រា ៥១៦, មាត្រា ១១៧៣ និងមាត្រា ៨៦២ នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់”*។ លិខិតយថាភូត គឺសំដៅដល់លិខិតទាំងឡាយណាដែលធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខា ក្រោយពេលខ្លួនបញ្ជាក់ថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់, លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី, មតកសាសន៍ដោយលិខិតយថាភូតធ្វើឡើងដោយកុងស៊ុលករណីជនជាតិខ្មែរនៅឯបរទេស ឬលិខិតដែលធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី។

លិខិតយថាភូតដែលធ្វើឡើងដោយសារការី ដែលត្រូវបានទទួលស្គាល់ដោយក្រមនីតិវិធីរដ្ឋប្បវេណី ថាមានតម្លៃជាលិខិតអនុវត្ត មាន ២ ប្រភេទ គឺលិខិតយថាភូតដែលធ្វើឡើងសម្រាប់ករណីសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ដែលមានចែងនៅក្នុងមាត្រា ៣៥០ និងករណីលិខិតយថាភូតដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគដែលមានចែងនៅក្នុងមាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ លិខិតសារការីដែលបានកំណត់ក្នុងមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ច នៃក្រមនីតិវិធីរដ្ឋប្បវេណី អាចក្លាយជាលិខិតអនុវត្តបាន ត្រូវបានកម្រិតចំពោះតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា **"កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ"** ប៉ុណ្ណោះ។ ដោយលិខិតសារការីទាំង ២ ប្រភេទនេះ ជាលិខិតអនុវត្ត, ច្បាប់កំណត់ឱ្យមន្ទីរសារការីដែលបានរក្សាទុកច្បាប់ដើមនៃលិខិតយថាភូត គឺជាអ្នកមានសមត្ថកិច្ចក្នុងការផ្តល់រូបមន្តអនុវត្តដើម្បីអនុវត្តដោយបង្ខំផ្អែកលើលិខិតយថាភូតនោះ[17]។ សារការីអាចផ្តល់រូបមន្តអនុវត្តពីរប្រភេទគឺ *រូបមន្តអនុវត្តធម្មតា* និង*រូបមន្តអនុវត្តពិសេស*។ សារការីប្រើប្រាស់រូបមន្តអនុវត្តពិសេសក្នុងករណីដែលសិទ្ធិលើបំណុលដែលមានកំណត់ក្នុងលិខិតអនុវត្តគឺជាសិទ្ធិលើបំណុលដែលភ្ជាប់លក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ឬក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវមានកូនបំណុល ឬម្ចាស់បំណុលនៃការអនុវត្តគឺជាភាគីផ្សេងក្រៅពីភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត។ សារការីអាចប្រើប្រាស់រូបមន្តអនុវត្តធម្មតានៅក្នុងករណីដែលលក្ខខណ្ឌណាមួយនៃរូបមន្តអនុវត្តពិសេសដូចដែលបានរៀបរាប់ខាងលើមិនត្រូវបានបំពេញទេ មានន័យថា បើសិនជាភាគីនៃការអនុវត្តដោយបង្ខំ (ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត) ដូចគ្នានឹងភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ឬសិទ្ធិលើបំណុលដែលអាចអនុវត្តដោយបង្ខំបានពុំមានភ្ជាប់លក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ។ ដោយផ្អែក ទៅលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំ នៅគ្រប់ទីកន្លែង និងមានអានុភាពដោយមិនមានរយៈពេលកំណត់។ បុគ្គលដែលមាន

---

17. មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ផលប្រយោជន៍មានសិទ្ធិធ្វើឧបាស្រ័យដូចជា ការតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តទៅតុលាការដែលមានសមត្ថកិច្ច[18]។

ហេតុដូចនេះ មិនមែនគ្រប់លិខិតសារការីសុទ្ធតែជាលិខិតអនុវត្តនោះទេ។ ប៉ុន្តែ ទោះបីជាលិខិតសារការីដែលមិនមានអានុភាពជាលិខិតអនុវត្តក៏ដោយ ការធ្វើលិខិតដោយសារការីអាចធានាបាននូវគោលដៅ ៣ យ៉ាងធំៗ។ ទីមួយ ការធានាបាននូវតុល្យភាព ប្រសិទ្ធភាព និងសុវត្ថិភាពគតិយុត្តដល់គូភាគីនៃលិខិត តាមរយៈកាតព្វកិច្ចរបស់សារការីក្នុងការផ្ទៀងផ្ទាត់ឯកសារ, ការផ្តល់ប្រឹក្សាមិនលម្អៀង និងតម្កល់ថែរក្សាច្បាប់ដើមនៃលិខិតទុក ជាដើម។ ទីពីរ ដោយសារតែជាលិខិតសារការីជាលិខិតដែលធ្វើឡើងដោយមន្ត្រីសាធារណៈដែលទទួលប្រតិភូកម្មអំណាចពីរដ្ឋ ហេតុនេះខ្លឹមសារនៃលិខិតសារការី គឺត្រូវតែមានភាពត្រឹមត្រូវតាមការពិត និងជឿជាក់បាន ពោលគឺមានអំណាចជាបន្ទាល់ទាក់ទងនឹងតម្លៃនៃភស្តុតាង និងមានកាលបរិច្ឆេទស្ថាពរ។ ទីបី អាចជួយបង្កើត និងបង្កើនជំនឿទុកចិត្តលើប្រព័ន្ធច្បាប់ និងកាត់បន្ថយជម្លោះក្នុងសង្គម។ ក្នុងន័យនេះហើយ ទើបច្បាប់តម្រូវឱ្យលិខិតមួយចំនួនត្រូវធ្វើឡើងតាមទម្រង់យថាភូត ដើម្បីអាចមានអានុភាព[19] និងអាចតតាំងជាមួយនឹងតតិយជនបាន។

## ខ- សារការីជាអ្នកប្រកបវិជ្ជាជីវៈសេរី

ផ្អែកតាមនិយមន័យនៃសារការីដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី សារការីគឺជាមន្ត្រីសាធារណៈ។ មិនទាន់មានច្បាប់ណាមួយបញ្ជាក់ថា សារការីគឺជាអ្នកប្រកបវិជ្ជាជីវៈសេរីនោះទេ។ ទោះបីជាសារការីជាមន្ត្រីសាធារណៈដែលទទួលប្រតិភូកម្មអំណាចសាធារណៈពីរដ្ឋ តែការប្រកបវិជ្ជាជីវៈរបស់សារការី គឺជាវិជ្ជាជីវៈសេរីផងដែរ ដោយក្នុងការផ្តល់នូវសេវាសាធារណៈក្នុងវិស័យច្បាប់ជូនដល់ប្រជាពលរដ្ឋដោយមិនក្លាយទៅជាបន្ទុកផ្នែកហិរញ្ញវត្ថុដល់រដ្ឋ សារការីមិនទទួលបានបៀវត្ស ឬប្រាក់ឧបត្ថម្ភណាមួយពីរដ្ឋនោះទេ។ សារការីទទួលបានចំណូលពីសកម្មភាព

---

18. កថាខណ្ឌទី៣ នៃមាត្រា ៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

19. កថាខណ្ឌទី២ នៃមាត្រា៣៣៦ នៃក្រមរដ្ឋប្បវេណី ចែងថា “ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិអចលនវត្ថុ នឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត”។

ប្រកបវិជ្ជាជីវៈរបស់ខ្លួន និងទទួលខុសត្រូវលើការខាត ឬចំណេញចំពោះដំណើរការនៃមន្ទីរដោយខ្លួនឯងផ្ទាល់។

ផ្អែកតាមអនុក្រឹត្យដែលបង្កើតមន្ទីរសារការីនីមួយៗ បានអនុញ្ញាតឱ្យមន្ទីរសារការីអាចអនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតក្រៅតែពីការធ្វើលិខិតយថាភូត និងលិខិតបញ្ជាក់។ សារការីប្រកបវិជ្ជាជីវៈរបស់ខ្លួន និងទទួលខុសត្រូវដោយឯករាជ្យគឺមិនស្ថិតនៅក្រោមការជ្រៀតជ្រែក ឬក្រោមឋានានុក្រមណាមួយឡើយ។ ទោះបីជាសារការីប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយសេរីក៏ដោយ ក្នុងនាមជាមន្ត្រីសាធារណៈដែលទទួលប្រតិភូកម្មអំណាចសាធារណៈពីរដ្ឋ សារការីត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋដើម្បីធានាថា សារការីអនុវត្តវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយភាពថ្លៃថ្នូរ សុចរិតទៀងត្រង់ និងផ្តល់អាទិភាពក្នុងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ និងការពារផលប្រយោជន៍ស្របច្បាប់របស់រដ្ឋ។ ការណ៏នេះបានធ្វើឱ្យសារការីប្រកបវិជ្ជាជីវៈសេរីក៏ពិតមែន ប៉ុន្តែមានលក្ខណៈខុសគ្នាពីការអនុវត្តវិជ្ជាជីវៈសេរីរបស់មេធាវី។ នៅក្នុងច្បាប់ជាធរមាន កម្រៃរបស់សារការីត្រូវបានកំណត់ដោយសេរីតាមការព្រមព្រៀងរវាងសារការី និងអតិថិជនរបស់ខ្លួន ព្រោះមិនទាន់មានបញ្ញត្តិណាមួយកំណត់អោយបានច្បាស់លាស់ឡើយ។ ការកំណត់លើអត្រាកម្រៃរបស់សារការីគឺកំពុងតែត្រូវបានរៀបចំនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី។ គោលបំណងនៃការកំណត់អំពីអត្រាកម្រៃរបស់សារការី គឺដើម្បីធានាថាប្រជាពលរដ្ឋគ្រប់រូបអាចប្រើប្រាស់បាននូវសេវាសាធារណៈដែលជាសមត្ថកិច្ចផ្តាច់មុខរបស់សារការីតាមការតម្រូវច្បាប់ ឬតាមឆន្ទៈរបស់ខ្លួនចំពោះកិច្ចដែលមិនមែនជាសមត្ថកិច្ច ផ្តាច់មុខរបស់សារការី។

## ២- អំពីកាតព្វកិច្ចរបស់សារការី

លោក Pierre-François REAL[20] បានហៅសារការី ថាជា *“អ្នកផ្តល់ការប្រឹក្សាមិនលម្អៀង និងតាក់តែងដោយអនាគតិ”* របស់គូភាគី ដែលធ្វើអោយពួកគេបានយល់នូវទំហំនៃ

20. Pierre-François REAL (១៧៥៧-១៨៣៤) គឺជាអ្នកតាក់តែងច្បាប់សារការីនៅប្រទេសបារាំង Loi 25 ventôse an XI (ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៨០៤)។ ច្បាប់នេះបានបង្កើតសារការីនៅក្នុងប្រទេសផ្សេងៗជាច្រើនក្រៅពីប្រទេសបារាំង ដូចជា បេលហ្ស៊ិក អាល្លឺម៉ង់

កាតព្វកិច្ចដែលពួកគេបានចុះកិច្ចសន្យា តាក់តែងនូវចំណងកិច្ចសន្យាដោយមានភាពច្បាស់លាស់ ផ្តល់ចរិតលក្ខណៈដល់លិខិតយថាភូត និងផ្តល់អានុភាពដូចសាលក្រមស្ថាពរដែលបិទសិទ្ធិមិនអោយមានបណ្តឹងឧបាស្រ័យ រក្សាអោយបានស្ថិតស្ថេរនូវការចងចាំ និងថែរក្សាតម្កល់ទុកលិខិតដែលតាក់តែងដោយសារការីប្រកបដោយភក្តីភាព បង្ការកុំអោយមានវិវាទកើតឡើងរវាងបុគ្គលស្លូតត្រង់។ ក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន, សារការីមានកាតព្វកិច្ចសំខាន់ៗ ដូចខាងក្រោមៈ

**ក-កាតព្វកិច្ចផ្ទៀងផ្ទាត់ ធានាភាពត្រឹមត្រូវ និងអនុលោមភាពនៃច្បាប់**

ក្នុងការតាក់តែងលិខិតយថាភូត, សារការីត្រូវផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់នូវឆន្ទៈពិតប្រាកដដោយមិនមានវិការៈរបស់ភាគី, អត្តសញ្ញាណភាគី និងសាក្សី, អត្តសញ្ញាណទ្រព្យ, ភាពត្រឹមត្រូវតាមច្បាប់នៃខ្លឹមសារ និងនិទ្ទេសដែលបានចុះក្នុងលិខិត, ភាពត្រឹមត្រូវនៃកាលបរិច្ឆេទនៃលិខិត និងភាពត្រឹមត្រូវនៃហត្ថលេខា ឬស្នាមមេដៃរបស់គូភាគី។ សេចក្តីអះអាងរបស់មន្ត្រីនេះ ក្នុងលិខិតនោះមានតំលៃខ្ពស់បំផុតដែលគេត្រូវជឿទុកចិត្តថាត្រឹមត្រូវ លើកលែងតែមានការប្តឹងចោទប្រកាន់ជាមុនថាជាលិខិតក្លែង។ បន្ថែមពីនេះ សារការីមានកាតព្វកិច្ចរៀបចំតាក់តែងខ្លឹមសារនៃលិខិត ឬកិច្ចព្រមព្រៀងអនុលោមទៅតាមលក្ខខណ្ឌខ្លឹមសារ និងលក្ខខណ្ឌទម្រង់ដែលច្បាប់តម្រូវ ដើម្បីធានាប្រសិទ្ធភាពនៃប្រតិបត្តិការ ព្រមទាំងផ្តល់ព័ត៌មានអំពីការគណនាពន្ធអាករលើប្រតិបត្តិការគតិយុត្ត ផ្ទៀងផ្ទាត់នូវការបង់អាករដើម្បីធានានូវការប្រមូលពន្ធអាករជូនរដ្ឋ។

ការធានាភាពត្រឹមត្រូវ ការបង្ការនូវការក្លែងបន្លំឯកសារ ការធានាភាពស្របច្បាប់នៃលិខិតដែលបានធ្វើនេះ ការផ្ទៀងផ្ទាត់នូវរាល់ឯកសារ និងព័ត៌មានសម្រាប់ការតាក់តែងលិខិតនោះ គឺជាគ្រឹះសម្រាប់បាននូវធានាសុវត្ថិភាពគតិយុត្តសម្រាប់គូភាគី និងបង្ការកុំឱ្យមានវិវាទនៅតុលាការដែលការណ៍នេះបានចូលរួមកាត់បន្ថយសោហ៊ុយ និងចំណេញពេលវេលាដល់គូភាគី

---

អាហ្សង់ទីន អូទ្រីស បៀគីណាហ្វាសូ្ស ឈីលី ខូឡុំប៊ី កូតឌីវ័រ អេស្ប៉ាញ ក្រិក អ៊ីតាលី លុចហ្សមប៊ួ ម៉ារ៉ុក មិកស៊ិក ហូឡង់ សាធារណរដ្ឋដូមីនិកេន រ៉ូម៉ានី សេនេហ្គាល់ និង ស្វីស។

និងចូលរួមកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ ព្រមទាំងធានានូវស្ថេរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

### ខ-កាតព្វកិច្ចបំភ្លឺ ផ្តល់ព័ត៌មាន និងផ្តល់ប្រឹក្សាដល់គូភាគីដោយសុចរិត ទៀងត្រង់ និងមិនលម្អៀង

សារការីមានកាតព្វកិច្ចត្រូវបំភ្លឺ ផ្តល់ព័ត៌មាន ផ្តល់ប្រឹក្សាយោបល់ច្បាប់ដោយមិនលម្អៀងដល់ភាគីទាំងអស់នៃលិខិតគតិយុត្ត អំពីខ្លឹមសារ និងលក្ខខណ្ឌ អំពីសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងផលវិបាក ឬអានុភាពគតិយុត្តនៃលិខិត ឬកិច្ចព្រមព្រៀងមុននឹងពួកគេចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ។ សារការីត្រូវពន្យល់អំពីទម្រង់ និងនីតិវិធីដែលតម្រូវដោយច្បាប់ដើម្បីធានាសុពលភាពស្របច្បាប់ និងអានុភាពអនុលោមទៅតាមគោលបំណងរបស់គូភាគី។

នៅក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំង ក្នុងនាមជាមន្ត្រីសាធារណៈ សារការីត្រូវបានគេហៅថាជា **"ចៅក្រមសម្រុះសម្រួល"**[21] ដែលមានតួនាទីការពារផលប្រយោជន៍គូភាគីទាំងសងខាងស្មើគ្នា ដែលផ្ទុយពីវិជ្ជាជីវៈមេធាវីដែលមានកាតព្វកិច្ចក្នុងការការពារផលប្រយោជន៍របស់អតិថិជនរបស់ខ្លួន[22]។ លោកស្រី Christiane Taubira អតីតរដ្ឋមន្ត្រីយុត្តិធម៌បារាំង (២០១២-២០១៦) បានថ្លែងនៅក្នុងសមាជលើកទី ១០៩ របស់សារការីនៃប្រទេសបារាំង ដោយបានលើកឡើងអំពីតួនាទីដ៏សំខាន់នៃវិជ្ជាជីវៈសារការីក្នុងការចូលរួមនូវសេវាផ្តល់ "សន្តិភាពស៊ីវិល (Paix Civile)"[23] តាមរយៈការលើកឡើងថា៖ «វិវាទទៅតុលាការសម្រាប់ប្រទេសប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក្នុងចំណោម ៣ កិច្ចសន្យា មាន ១ ប្តឹងគ្នាទៅតុលាការ ខណៈដែលនៅបារាំង ក្នុងចំណោមលិខិតសារការី ១០៧០ លិខិត ទើបមាន ១ ប្តឹងគ្នាទៅតុលាការ»។ ក្នុងវិស័យអចលនវត្ថុ វិវាទទៅតុលាការមាន ០,១% នៅស្រុកបារាំង ខណៈដែលនៅសហរដ្ឋអាមេរិកមានដល់ ៣០%។ ទិន្នន័យនេះ បានឆ្លុះបញ្ចាំងឱ្យឃើញអំពីតួនាទីដែលមិនអាចខ្វះបានរបស់សារការីនៃប្រព័ន្ធ Civil Law

---

21. សូមមើលគេហទំព័ររបស់ក្រុមប្រឹក្សាជាន់ខ្ពស់សារការី http://www.notaires.Fr

22. មាត្រា២ និងមាត្រា៣ នៃក្រមចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។

23. គេហទំព័រ https://mesinfos.fr/ile-de-france/109e-congres-des-notaires-de-france-c-taubira-reaffirme-le-role-de-la-profession-20976.html

នៅក្នុងសង្គមកម្ពុជាដែលជាតួអង្គសម្របសម្រួលដោះស្រាយវិវាទ កាត់បន្ថយជម្លោះ និងការបែកបាក់នៅក្នុងសង្គមគ្រួសារ និងសង្គមទាំងមូលតាមរយៈការផ្តល់ប្រឹក្សាយោបល់មិនលម្អៀងរបស់ខ្លួន ដើម្បីធានាផលប្រយោជន៍និងសមភាពដល់គូភាគីទាំងសងខាង ដែលផ្ទុយពីតួនាទីរបស់ស្នាក្តីនៅក្នុងប្រព័ន្ធ Common Law ដែលមានកាតព្វកិច្ចការពារតែផលប្រយោជន៍របស់អតិថិជនរបស់ខ្លួនដោយប្រកាន់ខ្ជាប់លើគោលការណ៍អ្នកណាខ្លាំងជាង អ្នកនោះនឹងឈ្នះ។

### គ- កាតព្វកិច្ចជៀសវាងនូវទំនាស់ផលប្រយោជន៍

សារការីត្រូវជៀសវាងរាល់ស្ថានភាពទាំងឡាយណាដែលអាចបង្កើតឱ្យមានជាទំនាស់ផលប្រយោជន៍។ ជាឧទាហរណ៍ នៅក្នុងមាត្រា ១១៧២ ចំណុច គ នៃក្រមរដ្ឋប្បវេណីដែលបានកំណត់ថា បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលិខិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការីនោះ មិនអាចធ្វើជាសាក្សី ឬជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍ឡើយ។ បើមិនដូច្នេះ បណ្តាំមតកសាសន៍ដែលមិនបានគោរពទៅតាមវិធានទម្រង់ដូចរៀបរាប់ខាងលើនេះ នឹងមិនមានសុពលភាពតាមផ្លូវច្បាប់ ត្រូវចាត់ទុកជាមោឃៈដែលមិនមានអានុភាពដើម្បីយកទៅអនុវត្តតាមគោលបំណងរបស់អតិថិជនឡើយ[24]។

### ឃ-កាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ

សារការី មានកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ។ ប៉ុន្តែ យោងតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងប្រឆាំងហិរញ្ញប្បទានភេរវកម្ម[25] ការសម្ងាត់វិជ្ជាជីវៈ មិនត្រូវរារាំងការអនុវត្តច្បាប់ និងមិនអាចយកមកប្រើជាសំអាង ដើម្បីបដិសេធការផ្តល់ព័ត៌មាន ដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងស្ថាប័នត្រួតពិនិត្យ ទោះបីសម្រាប់គោលបំណងសហប្រតិបត្តិការក្នុងប្រទេស អន្តរជាតិ ឬក៏ដូចដែលបានតម្រូវក្នុងការស៊ើបអង្កេតពាក់ព័ន្ធដល់ការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្មដែលត្រូវបានបញ្ជាដោយ ឬអនុវត្តក្រោមការត្រួតពិនិត្យរបស់តុលាការ។

---

24. មាត្រា១១៧០ និង១១៧១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

25. មាត្រា ៦ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧។

ផ្អែកតាមច្បាប់នេះ សារការីក៏បានដើរតួជាបុគ្គលរាយការណ៍ដែលត្រូវប្រកាន់យកវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួនឱ្យបានច្បាស់លាស់ នៅពេលដែលខ្លួនរៀបចំតាក់តែងប្រតិបត្តិការទាក់ទងនឹងសកម្មភាពបម្រើឱ្យអតិថិជនរបស់ខ្លួន ដូចជា កិច្ចសន្យាទិញលក់អចលនទ្រព្យ ឬបរធនបាលកិច្ច ជាដើម[26]។ ក្នុងករណីដែលសារការីមានមន្ទិលសង្ស័យធ្ងន់ធ្ងរ លើប្រភពស្របច្បាប់នៃមូលនិធិសម្រាប់ធ្វើប្រតិបត្តិការ សារការីអាចបដិសេធទទួលរៀបចំតាក់តែង ឬបញ្ជាក់លិខិតសារការីបាន ហើយសារការីមានកាតព្វកិច្ចត្រូវរាយការណ៍នូវប្រតិបត្តិការសង្ស័យ ឬប្រតិបត្តិការសាច់ប្រាក់ដែលលើសពីចំនួនកំណត់ដោយស្ថាប័នត្រួតពិនិត្យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។ ទោះបីជាមិនទាន់មានបទបញ្ញត្តិណាមួយបញ្ជាក់អំពីកាតព្វកិច្ចរក្សាការសម្ងាត់របស់សារការីក៏ដោយ ដោយសារសារការីជាបុគ្គលរាយការណ៍[27] ដូចដែលមានចែងនៅក្នុងច្បាប់នេះ ដែលជាករណីលើកលែងមួយ។ យើងអាចបកស្រាយផ្ទុយមកវិញបានថា ក្រៅពីករណីដែលច្បាប់បានកំណត់នេះ សារការីមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈដោយមិនមានសិទ្ធិបញ្ចេញរាល់គ្រប់មធ្យោបាយនូវព័ត៌មានទាក់ទងនឹងអតិថិជនរបស់ខ្លួនឡើយ។

### ង-កាតព្វកិច្ចក្នុងការរក្សាទុកឯកសារ និងតម្កល់ច្បាប់ដើមនៃលិខិត ព្រមទាំងឯកសារពាក់ព័ន្ធទុកក្នុងមន្ទីរសម្រាប់រយៈពេលតម្រូវដោយច្បាប់

សារការីមានទំនួលខុសត្រូវក្នុងការរក្សាទុកឯកសារដែលពួកគេផ្ទៀងផ្ទាត់ ដោយត្រូវធានាថាឯកសារទាំងនេះអាចត្រូវបានរកឃើញ និងប្រើប្រាស់ជាភស្តុតាងប្រសិនបើចាំបាច់។ មាត្រា ១៤ នៃច្បាប់ស្តីពីបណ្ណសា បានចែងអំពីការថែរក្សាទុកលិខិតសារការីមានរយៈពេល ៤០ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃឯកសារ។ មុខងារនេះមានសារៈសំខាន់ណាស់ ដើម្បីជៀសវាងជម្លោះ ការផ្លាស់ប្តូរឆន្ទៈរបស់គូភាគី និងការក្លែងបន្លំឯកសារ។ ឯកសារច្បាប់ដើមមានភាពច្បាស់លាស់ ពេញលេញ និងអនុលោមតាមច្បាប់ សារការីដែលជួយការពារជម្លោះដែលអាចកើតមានរវាងភាគីនេះ មានសារៈសំខាន់ណាស់ ជាពិសេសនៅក្នុងបរិបទដែលវិវាទអាចមានរយៈពេលវែង និងចំណាយច្រើនក្នុងការដោះស្រាយ។ ប្រសិនបើមានការបាត់បង់ ការខូចខាត

---

26. មាត្រា ៤, ៥, ៨ និងមាត្រា១០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០០៧។
27. មាត្រា ៤, ៥, ៨ និងមាត្រា១០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០០៧។

ឬបំផ្លាញលិខិតសារការី សារការីមានកាតព្វកិច្ចធ្វើឱ្យឡើងវិញនូវលិខិតសារការីដោយអនុលោមតាមលិខិតសារការីដែលបានទទួលរងការបាត់បង់ ខូចខាត ឬត្រូវបានបំផ្លាញនោះ។

## ៣-អំពីប្រតិបត្តិការដែលត្រូវធ្វើឡើងដោយសារការី

ផ្អែកលើតួនាទីដ៏សំខាន់របស់សារការីដូចបានគូសបញ្ជាក់ខាងលើ, ក្រមរដ្ឋប្បវេណី និងច្បាប់ជាធរមានផ្សេងទៀតនៅកម្ពុជា បានតម្រូវឱ្យលិខិតគតិយុត្ត ឬកិច្ចព្រមព្រៀងក្នុងវិស័យមួយចំនួន ជាពិសេស ក្នុងវិស័យអចលនវត្ថុ និងបេតិកភ័ណ្ឌគ្រួសារ ត្រូវតែធ្វើឡើងក្នុងទម្រង់ជាលិខិតយថាភូតរបស់សារការី ដើម្បីអាចមានសុពលភាព និង/ឬអាចមានអានុភាពតតាំងចំពោះតតិយជន។

### ក-នៅក្នុងវិស័យនីតិអចលនវត្ថុ

រាល់កិច្ចសន្យាអនុប្បទានកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិកាន់កាប់អចលនវត្ថុ[28] ជាអាទិ៍ កិច្ចសន្យាលក់ទិញអចលនវត្ថុ[29] ការដូរ[30] ហ៊ីប៉ូតែក[31] ការបញ្ចាំអចលនវត្ថុ[32] និងប្រទានកម្ម[33] សន្តតិកម្ម និងបណ្តាំមតកសាសន៍ដោយលិខិតយថាភូត[34] តម្រូវឱ្យធ្វើឡើងក្នុងទម្រង់ជាលិខិតយថាភូត។ នៅក្នុងប្រទេសកម្ពុជា ដែលទីផ្សារអចលនទ្រព្យកំពុងមានសន្ទុះខ្លាំង សារការីដើរតួនាទីយ៉ាងសំខាន់ក្នុងការតាក់តែងកិច្ចសន្យាទិញលក់ ហើយសារការីត្រូវផ្ទៀងផ្ទាត់ដូចជា៖

- មានការព្រមព្រៀងពិតប្រាកដរបស់គូភាគី ដោយមិនមានវិការៈ។

- អត្តសញ្ញាណរបស់គូភាគីដើម្បីបញ្ជាក់អំពីសមត្ថភាពរបស់ភាគីក្នុងការចាត់ចែងផ្ទេរសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិបានដោយអនុលោមតាមច្បាប់។

28. កថាខណ្ឌទី២ នៃមាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
29. មាត្រា៥១៦ និងមាត្រា៥២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
30. មាត្រា៥៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
31. មាត្រា៨៤៥ និងមាត្រា៨៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
32. មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
33. មាត្រា៥៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
34. មាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

- ផ្ទៀងផ្ទាត់អំពីឥណទានដែលយកមកប្រើប្រាស់នៅក្នុងប្រតិបត្តិការនៃការផ្ទេរប្រតិបត្តិការអចលនវត្ថុ និងថែរក្សានូវទ្រព្យមូលនិធិរបស់អតិថិជនដើម្បីធានាថានៅពេលដែលមានការផ្ទេរសិទ្ធិកាន់កាប់/សិទ្ធិកម្មសិទ្ធិរួចរាល់ហើយ ភាគីម្ខាងទៀតទទួលបានប្រាក់គ្រប់ចំនួន។

- ផ្ទៀងផ្ទាត់នូវរាល់ព័ត៌មានដើម្បីជៀសវាងប្រតិបត្តិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដូចដែលច្បាប់បានហាមឃាត់។

- ផ្ទៀងផ្ទាត់តម្លៃទិញលក់ និងកំណត់យន្តការនៃការបង់ប្រាក់។

- កំណត់អត្តសញ្ញាណកម្មវត្ថុនៃកិច្ចសន្យា រួមមានឯកសារបញ្ជាក់ការកាន់កាប់ ឬបញ្ជាក់សិទ្ធិកម្មសិទ្ធិ ទីតាំង ទំហំ អត្ថិភាពនៃសេវភាព ផលុបភោគ ការបញ្ចាំ ហ៊ីប៉ូតែក ឬ សិទ្ធិប្រត្យក្សផ្សេងទៀតដែលដាក់បន្ទុកទៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ។

- រៀបរាប់និងពន្យល់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីទាំងសងខាងដោយអព្យាក្រឹត្យមិនលម្អៀង ធានានូវតុល្យភាពនៃផលប្រយោជន៍របស់គូភាគីទាំងសងខាង។

- ផ្ទៀងផ្ទាត់ខ្លឹមសារនូវរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា និងធ្វើការចុះបញ្ជីអនុលោមទៅតាមលក្ខខណ្ឌទម្រង់ដែលតម្រូវដោយច្បាប់ដើម្បីធានានូវសុពលភាព និងអានុភាពនៃកិច្ចសន្យា។

តួនាទី និងកាតព្វកិច្ចរបស់សារការីក្នុងការផ្ទៀងផ្ទាត់ដូចរៀបរាប់ខាងលើនេះគឺដើម្បីធានានូវសុវត្ថិភាពគតិយុត្ត ធានានូវប្រសិទ្ធិភាពនៃប្រតិបត្តិការផ្ទេរសិទ្ធិកម្មសិទ្ធិដីធ្លី កាត់បន្ថយហានិភ័យនៃវិវាទដីធ្លី និងការក្លែងបន្លំឯកសារ ព្រមទាំងធានានូវការប្រមូលពន្ធរបស់រដ្ឋ។

### ខ- នៅក្នុងវិស័យនៃនីតិគ្រួសារ

ក្នុងនាមជាអ្នកជំនាញច្បាប់នៅក្នុងវិស័យនៃនីតិគ្រួសារ និងបេតិកភណ្ឌគ្រួសារ សារការីមិនត្រឹមតែផ្ដល់ប្រឹក្សាយោបល់លើការរៀបចំតាក់តែងកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធមុនពេលរៀបអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ប៉ុន្តែ សារការីក៏មានតួនាទីសំខាន់នៅអំឡុងពេលអាពាហ៍ពិពាហ៍ និងនៅពេលបញ្ចប់ចំណងអាពាហ៍ពិពាហ៍ដែលនាំឱ្យមានការជម្រះបញ្ជីទ្រព្យសម្បត្តិ ព្រមទាំងការផ្ទេរនូវទ្រព្យសម្បត្តិទាំងចលនទ្រព្យ និងអចលនទ្រព្យទៅឱ្យសន្តតិជន ឬអច្ច័យលាភីរបស់ខ្លួន។ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ សារការីអាចផ្ដល់ប្រឹក្សា

យោបល់ពីជម្រើសនៃការតាក់តែងប្រទានកម្ម ឬអច្ច័យទាន ការគ្រប់គ្រងបេតិកភណ្ឌ ជាអ្នកសម្រុះសម្រួលនៅក្នុងវិវាទគ្រួសារ ជាអ្នកតាក់តែងមតកសាសន៍ដោយលិខិតយថាភូត[35] ឬលិខិតសម្ងាត់[36] ឬមតកសាសន៍របស់បុគ្គលដែលមិនអាចនិយាយបានជាអាទិ៍[37] និងជាអ្នកជម្រះបញ្ជីនៅក្នុងពេលលែងលះ និងនៅក្នុងសន្តតិកម្ម។

ក្រមរដ្ឋប្បវេណី បានផ្ដល់នូវស្វ័យភាពដល់គូស្វាមីភរិយាក្នុងការជ្រើសរើសនូវប្រព័ន្ធទ្រព្យសម្បត្តិរបស់ខ្លួន[38]។ បើសិនជាសហព័ទ្ធមិនមានកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនោះទេ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នឹងត្រូវយកមកអនុវត្ត[39]។ ការផ្ដល់ប្រឹក្សាច្បាប់ទាក់ទងនឹងការតាក់តែងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺមានសារៈសំខាន់ណាស់ចំពោះសហព័ទ្ធដែលជាពាណិជ្ជករ ម្ចាស់ក្រុមហ៊ុន អាជីវករ បុគ្គលដែលអនុវត្តវិជ្ជាជីវៈសេរី (ដូចជាការិយាល័យមេធាវី ឬមន្ទីរសារការី ឬគ្លីនិកឯកជន ។ល។) ឬ សហព័ទ្ធដែលមានកូនច្រើនដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ផ្សេងៗគ្នា ព្រោះកិច្ចសន្យាប្រភេទនេះនឹងកំណត់ទុកជាមុនអំពីប្រភេទនៃទ្រព្យរបស់សហព័ទ្ធទាំងសងខាង អំពីសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធទាំងពីរ ដើម្បីធានានូវសុវត្ថិភាពគតិយុត្តដល់កូនដូចដែលបានរៀបរាប់ខាងលើ និងការពារសហព័ទ្ធម្ខាងពីហានិភ័យនៃការរឹបអូសទ្រព្យដើម្បីទូទាត់បំណុលដែលកើតចេញពីការក្ស័យធនណាមួយរបស់សហព័ទ្ធម្ខាងទៀតដែលជាកូនបំណុល។

នៅពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានរលត់ សារការីក៏មានតួនាទីសំខាន់ដើម្បីធានាថាការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅសន្តតិជន ឬអច្ច័យលាភី ត្រូវបានប្រព្រឹត្តទៅដោយរលូន ទោះបីជាទៅតាមឆន្ទៈរបស់មតកជន ឬទៅតាមច្បាប់។ តាមរយៈគោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិដែលប្រកាន់យកដោយក្រមរដ្ឋប្បវេណីរបស់កម្ពុជា សន្តតិជនត្រូវទទួលបន្តនូវ

---

35. មាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
36. មាត្រា១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
37. មាត្រា១១៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
38. មាត្រា៩៦៩ និងមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
39. មាត្រា ៩៧១ ដល់មាត្រា៩៧៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

សិទ្ធិនិងករណីយកិច្ចទាំងអស់នៅពេលដែលមតកជនទទួលមរណភាព[40]។ ការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅកាន់បុគ្គលផ្សេងទៀតដែលអាចជាសន្តតិជន ឬអច្ច័យលាភីដោយសន្តតិកម្ម អាចត្រូវបានធ្វើឡើងទៅតាមឆន្ទៈរបស់មតកជនតាមរយៈបណ្តាំមតកសាសន៍ ឬតាមច្បាប់បើសិនជាមតកជនមិនបានធ្វើបណ្តាំ[41]។ ការជជែកបែងចែកមតកក៏មិនតម្រូវឱ្យមានទម្រង់ជាក់លាក់ណាមួយឡើយ។ សន្តតិជនអាចធ្វើការជជែកពិភាក្សាបែងចែកមតកក៏ដោយផ្ទាល់មាត់ក៏បាន។ ប៉ុន្តែទាក់ទងនឹងការផ្ទេរសិទ្ធិចំពោះវត្ថុ ច្បាប់តម្រូវឱ្យមានការធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗដែលចាំបាច់ក្នុងការផ្ទេរសិទ្ធិចំពោះវត្ថុនោះ[42]។ បើសិនជាការពិភាក្សាបែងចែកមតករវាងសន្តតិជនពុំបានសម្រេច សន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមតកនោះបាន[43]។ សារការីដើរតួនាទីយ៉ាងសំខាន់ក្នុងសម្របសម្រួលរវាងសន្តតិជនដើម្បីឈានទៅដល់ការបែងចែកទ្រព្យសម្បត្តិប្រកបដោយសុខដុមរមនានៅក្នុងក្រុមគ្រួសារដែលជាកោសិកាដែលមិនអាចខ្វះបាននៅក្នុងសង្គម។ សារការីគឺជាអ្នកជំនាញច្បាប់ដែលទទួលបានការបណ្តុះបណ្តាលពិសេសទាក់ទងនឹងនីតិគ្រួសារ នីតិបេតិកភ័ណ្ឌគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិដែលទទួលបានប្រតិភូកម្មអំណាចពីរដ្ឋក្នុងតាក់តែងលិខិតយថាភូត និងលិខិតគតិយុត្តផ្សេងៗតាមការតម្រូវរបស់ច្បាប់ ឬ តាមការស្នើសុំរបស់បុគ្គល[44]។ ហេតុនេះ តាមការស្នើសុំរបស់សន្តតិជន ឬ អច្ច័យលាភី សារការីអាចដើរតួជាអ្នកជម្រះបញ្ជីតាមរយៈការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យរបស់មតកជន[45] ដើម្បីធ្វើការបែងចែកដល់សន្តតិជន ឬអច្ច័យលាភី តាមការព្រមព្រៀង ឬតាមច្បាប់ ឬតាមមតកសាសន៍។ បើសិនជាមានការព្រមព្រៀង និងស្នើសុំពីសន្តតិជនទាំងអស់ សារការីអាចចេញសេចក្តីចម្លងលិខិតបញ្ជាក់លក្ខណៈសម្បត្តិជាសន្តតិជន[46] ឬលិខិតបញ្ជាក់អំពីអចលនវត្ថុក្រោមទម្រង់យថាភូត ឬកិច្ចព្រមព្រៀងបែងចែកមត៌ក ឬលិខិតប្រគល់សិទ្ធិពីសន្តតិជន

---

40. មាត្រា១១៤៥ ដល់មាត្រា ១១៤៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

41. មាត្រា១១៥៧ ដល់មាត្រា ១១៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

42. មាត្រា ១២៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

43. មាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

44. មាត្រា ៣ នៃអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ ស្តីពីការបង្កើតមន្ទីរសារការី វាណិជ្ជនិងសហភាតា នៃព្រះរាជាណាចក្រកម្ពុជា។

45. មាត្រា១២១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

46. មាត្រា ៧៣០ កថាខណ្ឌ១ ដល់កថាខណ្ឌ៥ នៃក្រមរដ្ឋប្បវេណីបារាំង។

ម្នាក់ ឬច្រើនទៅសន្តតិជនណាម្នាក់ ឬបុគ្គលណាមួយទទួលចំណែកមត៌កជំនួស។ សេចក្តីចម្លង លិខិតបញ្ជាក់លក្ខណៈសម្បត្តិជាសន្តតិជន គឺជាលិខិតដែលសារការីបញ្ជាក់អំពីសមាសភាពនៃសន្តតិជន និងចំណែកដែលសន្តតិជនត្រូវទទួលបាននូវចំណែកសន្តតិកម្មរបស់ខ្លួន។ រីឯលិខិតបញ្ជាក់អំពីអចលនវត្ថុក្រោមទម្រង់យថាភូត គឺជាលិខិតដែលសារការីបញ្ជាក់អំពីការផ្ទេរនូវសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យពីមតកជនទៅកាន់សន្តតិជនតាមច្បាប់ ឬអច្ច័យលាភីតាមបណ្តាំមតកសាសន៍។ សារការីជាអ្នកទទួលបន្ទុកផ្ទៀងផ្ទាត់នូវវត្តមានមតកសាសន៍ ប្រទានកម្មដោយមូលហេតុមរណភាព ឬ អច្ច័យទាន ផ្ទៀងផ្ទាត់នូវលក្ខណៈសម្បត្តិរបស់សន្តតិជនតាមរយៈឯកសារអត្រានុកូលដ្ឋាន អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសាររបស់មតកជន សំបុត្រកំណើត លិខិតតំណវង្សត្រកូលមតកជន កិច្ចព្រមព្រៀងរបស់សហសន្តតិជន កិច្ចព្រមព្រៀងក្រុមប្រឹក្សាញាតិ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ព្រមទាំងសេចក្តីថ្លែងអះអាងរបស់សន្តតិជន ឬបុគ្គលដែលពាក់ព័ន្ធ។ នៅក្នុងការអនុវត្តជាក់ស្តែង លិខិតបញ្ជាក់លក្ខណៈសម្បត្តិជាសន្តតិជន ឬកិច្ចសន្យាស្តីពីការបែងចែកមត៌កត្រូវបានសន្តតិជន ឬសហសន្តតិជនយកទៅប្រើប្រាស់ជាមួយនឹងក្រសួង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនធានារ៉ាប់រង ទាំងនៅក្នុង និងនៅក្រៅប្រទេស ដើម្បីទទួលបាននូវការផ្ទេរសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ ឬការបង្វិលជាសាច់ប្រាក់សមតុល្យបន្ទាប់ពីការបំពេញទម្រង់ឯកសារដែលតម្រូវដោយគ្រឹះស្ថានទាំងនោះ។

បន្ថែមពីលើនេះទៀត វត្តមានរបស់សារការីគឺកាន់តែមិនអាចខ្វះបាននៅក្នុងការផ្តល់ប្រឹក្សាយោបល់ និងតាក់តែងនូវបណ្តាំមតកសាសន៍ដែលតាក់តែងឡើងដោយទម្រង់យថាភូត[47] និងមតកសាស៍ដោយលិខិតសម្ងាត់[48] ឬមតកសាសន៍របស់បុគ្គលដែលមិនអាចនិយាយបានជាអាទិ៍[49]។ សារការីអាចដើរតួជាអ្នកប្រតិបត្តិមតកសាសន៍ដែលអាចត្រូវបានកំណត់ដោយមតកសាសន៍[50] ឬដោយការជ្រើសតាំងដោយតុលាការ[51]។ ម្ចាស់បណ្តាំទទួលបាននូវ

47. មាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
48. មាត្រា១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
49. មាត្រា១១៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
50. មាត្រា១២១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
51. មាត្រា១២១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ការធានាថាឆន្ទៈពិតប្រាកដរបស់ខ្លួនត្រូវបានគោរពអនុវត្តតាមប្រកបដោយប្រសិទ្ធិភាព និងដោយរលូននៅពេលដែលខ្លួនទទួលមរណភាព តាមរយៈការទទួលបាននូវការប្រឹក្សាយោបល់ដោយល្អិតល្អន់ច្បាស់លាស់អំពីការលុបចោលឬការផ្តាច់មត៌ក[52] ការកំណត់ចំណែកមត៌ក[53] ការកំណត់នូវវិធីបែងចែកមត៌ក[54] ការហាមឃាត់នូវការបែងចែកមត៌ក[55] ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ការចាត់ចែងភាគបម្រុង និងភាគទំនេរនៃបេតិកភ័ណ្ឌរបស់ខ្លួនតាមរយៈអច្ច័យទានសកល ឬអច្ច័យទានពិសេស[56] ការបង្កើតវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធី[57] ការកាត់កាល់ឬទទួលស្គាល់កូន[58] ការកំណត់អ្នកមានអាណាព្យាបាល[59] នៅក្នុងករណីការការពារអសមត្ថជន ដូចជាកូនអនីតិជន ឬមានពិការភាព ឬមិនមាននីតិសម្បទាគ្រប់គ្រាន់ក្នុងការប្រកបអាជីវកម្មដែលតម្រូវឲ្យមានជំនាញជាក់លាក់ណាមួយ។ ឯកសារច្បាប់ដើមនៃបណ្តាំមតកសាសន៍ទាំងនោះ នឹងត្រូវតម្កល់នៅមន្ទីរសារការីប្រកបដោយសុវត្ថិភាពខ្ពស់។ ការបើកបណ្តាំមតកសាសន៍ដោយលិខិតយថាភូតរបស់សារការី អាចត្រូវបានធ្វើឡើងនៅក្រៅតុលាការ។ ក្រៅពីនេះ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ត្រូវដាក់ពាក្យសុំការបញ្ជាក់នៃលិខិត និងបើកលិខិតនៅតុលាការ។ បើមិនដូច្នេះទេ បុគ្គលនោះនឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន)រៀល[៦០]។ ការណ៍នេះសបញ្ជាក់ឲ្យឃើញអំពីតម្លៃនៃភាពជឿជាក់នូវលិខិតយថាភូតដែលតាក់តែងឡើងដោយសារការីដែលមានលក្ខណៈច្បាស់លាស់ និងជាក់លាក់។ ដើម្បីបើកបណ្តាំមតកសាសន៍ដោយលិខិតយថាភូត ឬដោយលិខិតសម្ងាត់ អ្នកស្នើសុំដែលអាចជាសន្តតិជន ឬអច្ច័យលាភី ត្រូវស្នើទៅសារការីដោយភ្ជាប់នូវសេចក្តីចម្លងសំបុត្រមរណភាពរបស់មតកជន ដើម្បីឱ្យសារការីធ្វើការកំណត់កាលបរិច្ឆេទបើក ជូនដំណឹង និងអញ្ជើញសន្តតិជន

---

52. មាត្រា១១៥១ ដល់មាត្រា១១៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
53. មាត្រា១១៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
54. មាត្រា១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
55. មាត្រា១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
56. មាត្រា១១៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
57. មាត្រា១១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
58. មាត្រា៩៩៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
59. កថាខណ្ឌ១ នៃមាត្រា១០៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
60. មាត្រា១២១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ឬអច្ច័យលាភី ព្រមទាំងសាក្សីដើម្បីចូលរួមបើកមតកសាសន៍នៅមន្ទីរសារការី។ នៅពេលបើកបណ្ដាំមតកសាសន៍ សារការីនឹងធ្វើនូវឯកសារដូចជា៖ (១)- កំណត់ហេតុបើកមតកសាសន៍ និងសេចក្ដីចម្លងកំណត់ហេតុជូនដល់សន្តតិជន អច្ច័យលាភី និងអ្នកប្រតិបត្តិមតកសាសន៍, (២)-សេចក្ដីចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃមតកសាសន៍ជូនអ្នកប្រតិបត្តិមតកសាសន៍ ដើម្បីប្រើប្រាស់នៅតាមក្រសួង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនធានារ៉ាប់រង, (៣)-បញ្ជាក់លើពាក្យសុំផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយមតកសាសន៍សម្រាប់សន្តតិជន ជូនអ្នកប្រតិបត្តិមតកសាសន៍ ដើម្បីដាក់ជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី, (៤)-លិខិតបញ្ជាក់ការចាត់ចែងទ្រព្យផ្សេងទៀត ដូចជារថយន្ត គណនីធនាគារ ជាអាទិ៍ ជូនអ្នកប្រតិបត្តិមតកសាសន៍ ដើម្បីដាក់ជូនក្រសួងដែលមានសមត្ថកិច្ចពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង ជាដើម និង (៥)-លិខិតអមដែលភ្ជាប់ឯកសារពាក់ព័ន្ធនឹងសន្តតិកម្មទាំងមូលជូនអ្នកប្រតិបត្តិមតកសាសន៍។

### គ- នៅក្នុងនីតិក្រុមហ៊ុន

ការបង្កើត និងការផ្លាស់ប្ដូរលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវធ្វើឡើងតាមទម្រង់លិខិតសារការី[61]ដែលអាចបង្កើតសុវត្ថិភាពផ្លូវច្បាប់ខ្ពស់ដល់ពាណិជ្ជករបាន។ អ្នកវិនិយោគមិនថាក្នុងស្រុក ឬបរទេស ត្រូវការការធានាសុវត្ថិភាពផ្នែកច្បាប់រឹងមាំ។ សារការីធានានូវអនុលោមភាពនៃឯកសាររបស់ក្រុមហ៊ុន សេចក្ដីព្រាងលក្ខន្តិកៈ និងវិញ្ញាបនប័ត្រនៃកិច្ចសន្យាពាណិជ្ជកម្ម ដើម្បីលើកកម្ពស់បរិយាកាសនៃការជឿទុកចិត្តគ្នាលើប្រតិបត្តិការអាជីវកម្មនៃដៃគូវិនិយោគតាមរយៈការបញ្ជាក់ពីភាពស្របច្បាប់ និងសុពលភាពរបស់ឯកសារពាក់ព័ន្ធ។ សុវត្ថិភាពគតិយុត្ត និងទំនុកចិត្តគឺជាចលករមួយយ៉ាងសំខាន់ក្នុងការទាក់ទាញការវិនិយោគពីបរទេស និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។

បន្ថែមពីនេះទៀត ដើម្បីធានានូវសុវត្ថិភាពក្នុងការថែរក្សា កាន់កាប់ គ្រប់គ្រង ចាត់ចែង និងផ្ទេរនូវទ្រព្យសម្បត្តិ ឬមូលនិធិនៅក្នុងគម្រោងវិនិយោគណាមួយ គម្រោងអភិវឌ្ឍន៍ណាមួយ

---

61. មាត្រា ៨២, ៩៧, ១០១ និងមាត្រា ១១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ដើម្បីជាផលប្រយោជន៍សាធារណៈ អង្គការ-សមាគម មនុស្សជាតិ ឬផលប្រយោជន៍របស់បុគ្គលជាក់លាក់ណាមួយដូចជាអនីតិជន ឬអសមត្ថជនផ្សេងទៀត ច្បាប់ស្តីពីបរធនបាលកិច្ចត្រូវបានបង្កើតឡើង[62]។ លិខិតបរធនបាលកិច្ច[63] មាន ២ ប្រភេទ គឺ លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពីការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដែលត្រូវបានធ្វើឡើងរវាងបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាល ដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬមេឃុំ ចៅសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន និងលិខិតមតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។ ដោយសារយន្តការនេះត្រូវបានបង្កើតឡើងដើម្បីបម្រើដល់ផលប្រយោជន៍ផ្សេងៗពីគ្នា បរធនបាលកិច្ចត្រូវបានបែងចែកជា ៤ ប្រភេទ[64] រួមមានៈ ១-បរធនបាលកិច្ចពាណិជ្ជកម្ម, ២-បរធនបាលកិច្ចសាធារណៈ ៣-បរធនបាលកិច្ចសង្គម និង ៤-បរធនបាលកិច្ចបុគ្គល។ សេវារក្សាទុកទ្រព្យសម្បត្តិ ឬមូលនិធិដោយមន្ទីរសារការីដើម្បីផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាល ហើយបរធនបាលត្រូវផ្ទេរត្រឡប់ឱ្យទៅបុគ្គលនោះវិញ ឬឱ្យទៅបុគ្គលណាមួយផ្សេងទៀត ត្រូវបានចាត់ទុកនៅក្នុងប្រភេទនៃបរធនបាលកិច្ចពាណិជ្ជកម្ម[65]។ ម្យ៉ាងទៀត អ្នកវិនិយោគិនបរទេសដែលមានបំណងធ្វើការវិនិយោគផ្នែកអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា ក៏អាចជ្រើសរើសយកនូវយន្តការនៃបរធនបាលកិច្ចពាណិជ្ជកម្មនេះ ដើម្បីឱ្យបរធនបាលធ្វើការកាន់កាប់ទ្រព្យសម្បត្តិ ឬមូលនិធិតម្កល់ដើម្បីជាប្រយោជន៍របស់វិនិយោគិនអ្នកទិញអចលនវត្ថុ និងដើម្បីប្រតិបត្តិការពាណិជ្ជកម្មផ្សេងៗទៀត[66]។ ក្នុងករណីការពារកូនជាអនីតិជន ឬអសមត្ថជនផ្សេងទៀត ឬសន្តតិជនឬអច្ឆ័យលាភីដែលមិនមានជំនាញច្បាស់លាស់នៅក្នុងការទទួលនូវសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិដែលតម្រូវឱ្យមានជំនាញ និងបច្ចេកទេសជាក់លាក់ ឪពុកម្តាយ ឬអាណាព្យាបាល អាចជ្រើសរើសយកនូវយន្តការបរធនបាលនេះដើម្បីធ្វើ

---

62. ច្បាប់ស្តីពីបរធនបាលកិច្ច ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ ២០១៩។

63. មាត្រា១៣ នៃច្បាប់ស្តីពីបរធនបាលកិច្ច។

64. មាត្រា៩ នៃច្បាប់ស្តីពីបរធនបាលកិច្ច។

65. មាត្រា១០ កថាខណ្ឌ២ ចំណុច ក នៃច្បាប់ស្តីពីបរធនបាលកិច្ច។

66. មាត្រា១០ កថាខណ្ឌ២ ចំណុច ខ នៃច្បាប់ស្តីពីបរធនបាលកិច្ច។

ការគ្រប់គ្រងនូវទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួន ហើយធ្វើការផ្ទេរនូវផល ឬទ្រព្យសម្បត្តិ ឬមូលនិធិទាំងនោះ ដើម្បីជាប្រយោជន៍ដល់បុគ្គលដូចដែលបានរៀបរាប់ខាងលើតាមរយៈការបង្កើតជាបរធនបាលកិច្ចសាធារណៈ[67]។ លិខិតបរធនបាលកិច្ចត្រូវធ្វើឡើងក្នុងទម្រង់លាយលក្ខណ៍អក្សរដែលត្រូវមានការបញ្ជាក់ពីសារការីដែលជាតួអង្គមួយក្នុងចំណោមតួអង្គផ្សេងទៀតដែលច្បាប់បានកំណត់[68]។

ក្រៅពីករណីខាងលើ សារការីក៏មានតួនាទីសំខាន់ផងដែរក្នុងការតាក់តែងកិច្ចសន្យា ជាពិសេសកិច្ចសន្យាខ្ចីប្រាក់ ដែលលិខិតយថាភូតចំពោះករណីនេះ មានអានុភាពជាលិខិតអនុវត្ត ក្នុងករណីដែលបានបំពេញតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។

ជារួម សារការីនៅកម្ពុជា បានចាប់ផ្តើមចាក់ឫសឡើងវិញជាបណ្តើរៗនៅក្នុងសង្គមកម្ពុជា ទោះបីជាវិជ្ជាជីវៈមួយនេះមិនទាន់ត្រូវទទួលស្គាល់យ៉ាងទូលំទូលាយក៏ដោយ។ ដោយបច្ចុប្បន្ន ចំនួនមន្ទីរសារការី, ចំនួនសារការី និងចំនួនមន្ត្រីទទួលបន្ទុកកិច្ចការសារការី នៅមានកំណត់ដែលមិនទាន់អាចឆ្លើយតបបានទាំងស្រុងទៅតម្រូវការរបស់ប្រជាពលរដ្ឋ, មេឃុំ ចៅសង្កាត់ និងអភិបាលក្រុង-ស្រុក-ខណ្ឌ បានបន្តដើរតួនាទីសំខាន់ ស្របតាមទំនៀមទម្លាប់របស់ច្បាប់កម្ពុជា តាំងពីបុរាណមក ក្នុងការបញ្ជាក់លើលិខិតផ្សេងៗ ជាអាទិ៍ លិខិតលក់ផ្តាច់ អំណោយផ្តាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យាបង្កើតសេវភាព និងផលុបភោគ។ ដើម្បីលើកកម្ពស់វិជ្ជាជីវៈនេះ ច្បាប់ស្តីពីលក្ខន្តិកៈសារការី នឹងត្រូវបង្កើតឡើងនាពេលខាងមុខ សម្រាប់ជាមូលដ្ឋានគតិយុត្តដ៏រឹងមាំក្នុងការគ្រប់គ្រងវិជ្ជាជីវៈនេះ ជាពិសេស ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនេះឱ្យបានល្អ ដើម្បីធានាថាសារការីនៅកម្ពុជាអនុវត្តមុខងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់ សំដៅធានាសុវត្ថិភាពគតិយុត្ត បង្ការ និងទប់ស្កាត់វិវាទ និងបង្កើនជំនឿទុកចិត្តលើប្រតិបត្តិការគតិយុត្ត ធានានូវតុល្យភាព តម្លាភាព ស្ថិរភាព និងសុខដុមរមនាភាពក្នុងសង្គម ព្រមទាំងការពារផលប្រយោជន៍របស់រដ្ឋ និងអ្នកប្រើប្រាស់សេវាសាធារណៈនៅក្នុងសង្គមនីតិរដ្ឋ។

---

67. មាត្រា១១ នៃច្បាប់ស្តីបរធនបាលកិច្ច។
68. មាត្រា១៣ នៃច្បាប់ស្តីបរធនបាលកិច្ច។